www.kidworship.kr

# អាដាមនិងអេវ៉ា

- 2nd Story -


11Page

**Nar** នៅក្នុងសួនច្បារអេដែន មានពេញដោយដើមឈើ
មានផ្លែនិងផ្កាគ្រប់ប្រភេទ
ហើយមានទន្លេដ៏ស្រស់ស្អាតមួយ ហូរកាត់តាមសួនច្បារនោះ។
គ្រប់សត្វទាំងអស់បានរស់នៅជាមួយគ្នាយ៉ាងរីករាយ។
នៅចំកណ្តាលសួនច្បារអេដែន មានដើមឈើដឹងខុសត្រូវមួយ។
ឯអាដាមបានរស់នៅយ៉ាងរីករាយនៅក្នុងសួនច្បារនោះ។
ព្រះជាម្ចាស់បានប្រាប់ទៅអាដាមនៅក្នុងសួនច្បារនោះថា

**God** ឯងអាចញ៉ាំផ្លែឈើណាក៏បាននៅក្នុងសួនច្បារអេដែននេះ
ប៉ុន្តែឯងមិនត្រូវញ៉ាំផ្លែឈើដឹងខុសត្រូវជាដាច់ខាត។
បើថ្ងៃណាមួយឯងញ៉ាំផ្លែឈើដឹងខុសត្រូវនេះហើយ
នោះឯងនឹងត្រូវស្លាប់ជាមិនខាន។

**Adam** បាទព្រះអម្ចាស់!

---


12Page

**Nar** ថ្ងៃមួយ ព្រះជាម្ចាស់បានមើលឃើញថា
«បើអាដាមជាមនុស្សប្រុសរស់នៅតែម្នាក់ឯង ដូច្នេះមិនល្អទេ»។
ហេតុនេះហើយ ពេលអាដាមកំពុងដេកលក់
ព្រះអង្គបានដកយកឆ្អឹងជំនីរបស់អាដាម មកបង្កើតជាមនុស្សស្រី
ដែលមានឈ្មោះថា «អេវ៉ា»។
ទោះបីអាដាមនិងអេវ៉ានៅខ្លួនទទេ ប៉ុន្តែពួកគេមិនអៀនខ្មាស់ទេ។

---


13Page

**Nar** មានថ្ងៃមួយ ពស់បានមកជួបនឹងអេវ៉ា។

**Serpent** តើព្រះជាម្ចាស់ពិតជាបាននិយាយនិងអ្នកថា
មិនត្រូវញ៉ាំផ្លែឈើទាំងប៉ុន្មាន ដែលនៅក្នុងសួនច្បារនេះ
មែនឬទេ?

**Eve** អត់ទេ! យើងអាចញ៉ាំផ្លែឈើក្នុងសួនច្បារនេះ
មួយណាក៏បាន តែព្រះជាម្ចាស់បាននិយាយថា
ឯងមិនត្រូវញ៉ាំឬប៉ះផ្លែឈើដឹងខុសត្រូវនោះទេ
បើឯងញ៉ាំវា នោះឯងនឹងស្លាប់ជាមិនខាន។

**Serpent** អត់ទេ! វាមិនដូច្នោះទេ!
សាកញ៉ាំវាមើល៍! អ្នកនឹងមិនស្លាប់ទេ។
ព្រះជាម្ចាស់ដឹងថា នៅពេលណាដែលអ្នកញ៉ាំផ្លែឈើដឹងខុសត្រូវនេះ

នោះភ្នែកអ្នកនឹងបានភ្លឺឡើងហើយអ្នកនឹងបានដូចជាព្រះ
ដែលស្គាល់ល្អស្គាល់អាក្រក់ជាមិនខាន។

**Eve** ពិតមែនឬ..? តើអ្នកនិយាយពិតមែនឬទេ?

**Serpent** ពិតមែន! មើលទៅផ្លែ
ឈើដឹងខុសត្រូវនោះណ៎....វាមើលទៅឆ្ងាញ់ណាស់។

**Nar** ពស់បានរៀបចំផែនការ ដើម្បីឲ្យអាដាមនិងអេវ៉ាបាន
ក្បត់សន្យាជាមួយព្រះជាម្ចាស់
ហើយអ្នកទាំងពីរបានធ្វើអំពើបាបទាស់ប្រឆាំង
ដោយបានញ៉ាំផ្លែឈើដឹងខុសត្រូវនោះ។
ដំបូង អេវ៉ាបានឃើញថា ផ្លែឈើដឹងខុសត្រូវនោះល្អ
និងជាទីពេញចិត្តដល់ភ្នែករបស់នាង។
ដូច្នេះ ចុងក្រោយ អេវ៉ាបានភ្លេចការរំលឹកដាស់តឿនរបស់ព្រះជាម្ចាស់ថា
បើសិនជានាងបានញ៉ាំផ្លែឈើដឹងខុសត្រូវនេះ
នោះនាងនឹងស្លាប់ជាមិនខាន។ ស្រាប់តែពេលនោះ
អេវ៉ាបានឈោងដៃចាប់បេះផ្លែឈើដឹងខុសត្រូវយកមកញ៉ាំហើយ។
ក៏បានឲ្យផ្លែឈើដឹងខុសត្រូវនោះ មកអោយអាដាមញ៉ាំដែរ។
ក្រោយពេល អាដាមបានញ៉ាំរួចហើយ នោះ
ក៏មានរឿងចំឡែកកើតឡើង។
អាដាមនិងអេវ៉ាបានដឹងខ្លួនថា ពួកគេនៅខ្លួនទទេ។
ពេលនោះ ពួកគេខ្មាស់អៀនហើយក៏បានដេរស្លឹកឈើ
មកពាក់បិតបាំងខ្លួនពួកគេ។
បន្ទាប់មក ពួកគេបានពួននៅក្នុងសួនច្បារអេដែន។
ព្រះជាម្ចាស់ទ្រង់ដឹងរឿងគ្រប់យ៉ាង ហើយព្រះអង្គក៏បានដឹងថា
អាដាមនឹងអេវ៉ាបានញ៉ាំផ្លែឈើដឹងខុសត្រូវរួចហើយ
ពេលនោះព្រះអង្គមិនសប្បាយចិត្តទេ។
ក្រោយមក ព្រះជាម្ចាស់បានហៅរកអាដាម។

**God** អាដាមអើយ! ឯងនៅឯណា?
តើឯងបានញ៉ាំផ្លែឈើដឹងខុសត្រូវហើយមែនទេ?

**Adam** បាទព្រះអម្ចាស់!
អេវ៉ាជាអ្នកឲ្យផ្លែឈើដឹងខុសត្រូវនោះមកខ្ញុំហើយខ្ញុំក៏បានញ៉ាំវាទៅ។

**God** អេវ៉ា! ហេតុអ្វីបានជានាងធ្វើដូច្នេះ?

**Eve** ព្រះអម្ចាស់អើយ! គឺពស់បានបោកបញ្ឆោតខ្ញុំឲ្យញ៉ាំវា។

**Nar** ព្រះជាម្ចាស់បានដាក់ទោសដល់អាដាមនិងអេវ៉ា
ដែលមិនបានរក្សាសន្យាជាមួយព្រះជាម្ចាស់។





15Page

ហើយព្រះជាម្ចាស់ក៏បានដាក់ទោសដល់ពស់នោះដែរ។

**God** ពស់អើយ! ឯងនឹងត្រូវវារដោយពោះរបស់ឯងពេញមួយជីវិត!
អេវ៉ា! នាងនឹងបង្កើតកូនទាំងឈឺចាប់បំផុត!
អាដាម! ឯងត្រូវរកស៊ីចិញ្ចឹមជីវិត
ទាំងហូរញើសរហូតដល់ឯងស្លាប់ទៅជាដីវិញ!

**Nar** ព្រះជាម្ចាស់បានធ្វើខោអាវពីស្បែកសត្វមកឲ្យអាដាមនិងអេវ៉ាពាក់។
ហើយព្រះជាម្ចាស់បានហាំអាដាមនិងអេវ៉ាមិនឲ្យ
ចូលទៅក្នុងសួនច្បារអេដែនទៀតទេ។
ទោះបីអាដាមនិងអេវ៉ាបានក្បត់សន្យាជាមួយព្រះជាម្ចាស់
និងបានធ្វើអំពើបាបក៏ដោយ ក៏ព្រះជាម្ចាស់នៅតែស្រលាញ់
និងមើលថែរក្សាអាដាមនិងអេវ៉ា រហូតដល់ទីបញ្ចប់។
ចាប់តាំងពីពេលនោះមក
អាដាមនឹងអេវ៉ា ក៏បានចាកចេញពីសួនច្បារអេដែននោះ
ហើយនៅពេលពួកគេស្លាប់ទៅ នោះពួកគេបានត្រលប់ទៅជាដីវិញ
ដូចតាមព្រះជាម្ចាស់បាននិយាយអញ្ចឹង។